# ECCC email accounts and Case 004/02

Megan HIRST

**Sent:** Monday, February 03, 2020 10:05 PM
**To:** Vanly CHET; Kimsuon Hong; Mengkhy Kim [Kim.Mengkhy@eccc.gov.kh]; CHUNTHY.Lor@eccc.gov.kh; Sokong SAM; Soworn Sim; Srinna Ty; Pov VEN; Laure DESFORGES; Isabelle Durand; Emmanuel JACOMY; Martine Jacquin [Jacquin.Martine@eccc.gov.kh]; Daniel MCLAUGHLIN; Lyma Nguyen; Nushin SAKARATI
**Cc:** Ang PICH; Lauren TIPTON; Sothie KEO; Sothearith SNGUON; Socheata NUON
**Importance:** High

**ENGLISH BELOW**

សូមជម្រាបជូនលោក លោកស្រីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី,

យើងខ្ញុំបានទំនាក់ទំនងទៅលោក លោកស្រី កាលពីប៉ុន្មានសប្ដាហ៍មុន ដើម្បីចង់ដឹងថា តើលោក លោកស្រី អាចបើកអ៊ីម៉ែល និងចូលមើលសំណុំរឿងតាមប្រព័ន្ធអេឡិចត្រូនិចរបស់សាលាក្ដីបានឬអត់។ យើងខ្ញុំដឹងថា ក្នុងចំណោមមេធាវីទាំងអស់ មានមេធាវីជាច្រើនរូបដែលកំពុងមានបញ្ហាក្នុងការចូលមើលអ៊ីម៉ែល និងប្រព័ន្ធអេឡិចត្រូនិចនេះ។ ដូច្នេះហើយ យើងខ្ញុំបាននិងកំពុងស្វែងរកអំពីវិធីដោះស្រាយបញ្ហាទាំងនេះ។

**ប្រសិនបើ លោក លោកស្រីមិនអាចចូលមើលអ៊ីម៉ែលរបស់សាលាក្ដីបានទេ សូមលោក លោកស្រីមេត្តាទំនាក់ទំនងទៅលោកស្រី ហេង យូឡេង តាមអ៊ីម៉ែល HENG.Youleng@eccc.gov.kh និងលោកស្រី កាំង ម៉ូនីដា តាមរយៈអ៊ីម៉ែល KAING.Monida@eccc.gov.kh នៅអង្គភាពគាំពារជនរងគ្រោះ ហើយប្រាប់អំពីបញ្ហារបស់លោក លោកស្រីឲ្យពួកគេបានដឹង (ឧ. អ៊ីម៉ែលត្រូវផុតកំណត់ ប្រអប់អ៊ីម៉ែលពេញ មិនអាចចូលមើល Zylab បាន ។ល។)។** ពេលនោះ អង្គភាពគាំពារជនរងគ្រោះ នឹងទាក់ទងទៅផ្នែកព័ត៌មានវិទ្យា ឬប្រាប់លោក លោកស្រីអំពីអ្នកដែលត្រូវទាក់ទង តាមបញ្ហាដែលបានកើតឡើង។

យើងខ្ញុំសូមស្នើឲ្យ លោក លោកស្រី អនុវត្តតាមជំហានទាំងនេះឲ្យបានឆាប់តាមដែលអាចធ្វើបាន ហើយសូម ជូនដំណឹងមកយើងខ្ញុំឲ្យបានដឹងផង ប្រសិនបើលោក លោកស្រីមានបញ្ហាពិបាកអ្វីផ្សេងទៀត។ យើងខ្ញុំ ជឿថា វាមានសារៈសំខាន់ណាស់សម្រាប់លោក លោកស្រីក្នុងការចូលមើលអ៊ីម៉ែលរបស់ខ្លួននិងចូលមើល Zylab បាន។ បើមិនដូច្នោះទេ លោក លោកស្រីអាចបាត់ព័ត៌មាន មិនដឹងពីការឆ្លើយឆ្លងគ្នារវាងភាគី និងការដាក់ឯកសារផ្សេងៗឡើយ។ ការណ៍នេះ គឺវាអនុលោមតាមសេចក្ដីណែនាំរដ្ឋបាល ស្ដីពីការប្រែប្រួលព័ត៌មាន ការចាត់ចំណាត់ថ្នាក់ និងការដោះស្រាយ។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំចង់ប្រាកដប្រជាថា លោក លោកស្រី បានដឹងអំពីការវិវត្តថ្មីៗ ដែលកើតឡើងនៅក្នុងសំណុំរឿង ០០៤/០២។ ខាងក្រោមនេះ គឺជាអ្វីដែលយើងខ្ញុំបានផ្ញើជូនលោក លោកស្រីតាមរយៈអ៊ីម៉ែល កាលពីប៉ុន្មានសប្ដាហ៍កន្លងទៅ។

- យើងបានទទួលសារណាច្បាប់ចម្លងរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ (១) នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។
- សារណានោះ យោងទៅលើការស្នើសុំដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០១៩ ក្នុងការសុំពេលវេលាបន្ថែម សម្រាប់ដាក់បញ្ជី តាមវិធាន ៨០ និងសម្រាប់ការរៀបចំប្រជុំរៀបចំសវនាការ។ យើងខ្ញុំបានស្នើសុំសារណាច្បាប់ចម្លងនេះដែរ ពីសហព្រះរាជអាជ្ញាអន្តរជាតិ ប៉ុន្តែ មិនទាន់បានទទួលការឆ្លើយតបនៅឡើយទេ។
- នៅថ្ងៃទី២០ ខែមករា មេធាវីការពារក្ដី អោ អាន បានផ្ញើអ៊ីម៉ែលអំពីសេចក្ដីសង្ខេបនៃការជំទាស់បឋមរបស់ពួកគេតាមវិធាន ៨៩។
- ការជំទាស់បឋមរបស់មេធាវីការពារក្ដី យោងទៅលើលិខិតមួយដែលបានផ្ញើដោយមេធាវីការពារក្ដីទៅអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។ យើងខ្ញុំមិនបានទទួលលិខិតនេះពីមេធាវីការពារក្ដីឡើយ។
- កាលពី ថ្ងៃទី២៨ ខែមករា យើងខ្ញុំបានទទួលអ៊ីម៉ែលមួយពី មេធាវីការពារក្ដី អោ អាន ដោយមានភ្ជាប់សារណារបស់ពួកគេស្ដីពីបញ្ជីសាក្សី អ្នកជំនាញ អនុលោមតាមវិធាន ៨០។
- សារណារបស់មេធាវីការពារក្ដី យោងទៅលើអ៊ីម៉ែលមួយដែលបានផ្ញើកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ដោយមន្ត្រីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបញ្ជាក់ថា អង្គបុរេជំនុំជម្រះ មិនបានបញ្ជូនសំណុំរឿង មកកាន់អង្គជំនុំជម្រះសាលាដំបូងទេ។

ចំពោះលោក លោកស្រីមេធាវីណា ដែលមិនអាចចូលមើលអ៊ីម៉ែលសាលាក្ដីរបស់ខ្លួនបាន៖ សូមជួយជូនដំណឹងមកយើងខ្ញុំផង នៅពេលដែលលោក លោកស្រីអាចបើកអ៊ីម៉ែលរបស់ខ្លួនបាន ហើយយើងខ្ញុំ នឹងផ្ញើឯកសារពាក់ព័ន្ធជូនលោកលោកស្រីម្ដងទៀត។

យើងខ្ញុំសូមបញ្ជាក់ថា ពេលនេះគឺនៅតែមានភាពមិនប្រកដប្រជាថាតើ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០៤/០២ ឬនៅ។ បន្ថែមពីលើនេះទៅទៀត ការិយាល័យរដ្ឋបាលបានជំរាបប្រាប់ពួកខ្ញុំថា ពួកគាត់មិនបានកត់សំគាល់ថាពួកខ្ញុំជាមេធាវីនាំមុខ ក្នុងសំណុំរឿង ០០៤/០២ ទេ។ ដូច្នេះ ពួកយើងខ្ញុំនឹង ស្នើគូភាគី ឲ្យរាប់បញ្ចូលលោកលោកស្រីទាំងអស់គ្នាក្នុងការឆ្លើយឆ្លង។

ដោយក្ដីគោរព

Dear CPL

We've been in touch with some of you in the past weeks to check whether you are able to access emails and filings in the ECCC system. We are aware that many of you are having difficulties and we've been looking into how these can be fixed.

**If you are not able to access your ECCC emails, please contact Youleng HENG <HENG.Youleng@eccc.gov.kh> and Monida KAING <KAING.Monida@eccc.gov.kh> in VSS, and identify the problem with your account (eg expiry, mailbox full, unable to access zylab, etc).** VSS will then liaise with ICT or direct you to the correct person in ICT, depending on what the problem is.

We request that you take these steps as soon as possible and please let us know if you have any difficulties. We believe it is essential for you to be able to use your ECCC email and Zylab accounts. You may otherwise be unaware of *inter partes* communications and filings. We will also continue to use only your ECCC email addresses for any confidential material or material which we believe may be confidential. This is in compliance with the Administrative Guideline on Information sensitivity, classification and handling.

In the meanwhile we wanted to make sure you are aware of the developments which are occurring in Case 004/02. These have been the subject of some emails sent to your ECCC accounts in recent weeks.

- We received a courtesy copy of an rule 80(1) submission and list of witnesses, experts and civil parties sent by the International Co-Prosecutor (ICP) on 13 January.
- The rule 80(1) submission refers to a request made by the ICP on 26 December 2019 for an extension of time for rule 80 lists and for a trial management meeting to be convened. We requested a copy of this request from the ICP but have not received a response.
- On 20 January the AO An defence emailed a summary of their rule 89 preliminary objections.
- The defence summary of preliminary objections refers to a letter sent by the defence to the Trial Chamber on 30 December 2019. We have not received this letter from the Defence.
- On 28 January we received an email from AO An defence attaching their rule 80 witness and expert list submissions.
- The defence submissions refer to an email which was sent on 21 January 2020 by the Trial Chamber Greffier, stating that the PTC has not yet forwarded the case file to the TC.

**For those who have been unable to access their ECCC accounts: once these are reactivated kindly contact us to inform us and we will re-send any of the documents which did not reach you because of problems with your account.**

**We note that at the present time it remains controversial whether the Trial Chamber is seised with Case 004/02. In addition, the Office of Administration has informed us that they do not currently consider us to be designated as**

**Lead Co-Lawyers in respect of Case 004/02. We therefore intend to ask that the parties continue to include you directly on any correspondence.**

Kind regards

**Megan Hirst**
International Civil Party Lead Co-Lawyer
Extraordinary Chambers in the Courts of Cambodia
Email: hirst.megan@eccc.gov.kh / Ext: 6484